# អនុសាសន៍របស់លោកអភិបាលអូលីវីយេ
# ក្នុងសិក្ខាសាលាអំពីបរិស្ថាននៅចំការទៀង
# ថ្ងៃទី១៥ មករា ២០១៧

ជាបឋមសូមគោរពលោកអនុប្រធានមន្ទីរបរិស្ថានខេត្តតាកែវ សូមគោរពលោកគ្រូអ្នកគ្រូ លោកមេភូមិនិងបងប្អូនទាំងអស់ ដែលបានចូលរួមនៅក្នុងសិក្ខាសាលាស្តីពីបរិស្ថាននេះ។ ខ្ញុំសង្ឃឹម សិក្ខាសាលានេះ បងប្អូនបានចាប់អារម្មណ៍ខ្លះៗ និងណែនាំឲ្យយើងមានកម្លាំងថ្មី។

នៅពេលយើងធ្វើដំណើរគ្រប់ទីកន្លែង មានកន្លែងខ្លះគេបានសរសេរផ្លាកថាហាមចោលសម្រាម តែកន្លែងនោះជាកន្លែងដែលមានសម្រាមច្រើនជាងគេ។ នៅជនបទយើងឥតមានក្រុមហ៊ុនប្រមូលសម្រាម តែបើបងប្អូនធ្វើដំណើរទៅភ្នំពេញថ្មី យើងឃើញមានសម្រាមច្រើនណាស់ យើងមានភ្នំសម្រាមនៅជាប់ផ្ទះបងប្អូន មានគោក៏ស៊ី មនុស្សក៏ទៅរកអេតចាយ ណែនាំឲ្យយើងយូរៗសាំអស់ហើយ។ ហេតុនេះហើយយើងត្រូវការភ្ញាក់អំពីបញ្ហានេះ សម្តេចប៉ាបប្រាំង់ស៊ីស្កូ បានសរសេរសាលិខិតជូនដល់ពិភពលោកទាំងមូល ដើម្បីគិតអំពីបរិស្ថាន ជាពិសេសអំពីរបៀបដែលរៀងៗខ្លួនត្រូវទទួលខុសត្រូវ។

ពេលខ្ញុំធ្វើដំណើរទៅអង្គស្នួល ខ្ញុំភ្ញាក់ដោយសារនៅខាងកើត ខ្ញុំឃើញព្រះអាទិត្យរះ និងខាងលិច ខ្ញុំឃើញព្រះច័ន្ទរៀបលិច មានដើមត្នោត មានផ្កាស្រស់បំព្រង នេះជាទ្រព្យសម្បត្តិយ៉ាងពិសេសដែលយើងបានទទួល នឹងត្រូវតែការពារថែរក្សា។ ឃ្លាមួយក្នុងលិខិតរបស់សម្តេចប៉ាបបានសេរសេរ គឺ "**ផែនដីជាបងស្រីនេះ កំពុងតែស្រែកព្រោះយើងបានបំផ្លាញគាត់ គឺយើងប្រើប្រាស់សម្បត្តិដែលព្រះជាម្ចាស់បានកប់ទុកក្នុងគាត់ ដោយមិនចេះទទួលខុសត្រូវ និងដោយតែងតែប្រើប្រាស់ហួសហេតុ។ យើងធំធាត់ឡើងទាំងនឹកគិតថា យើងអាចកាន់កាប់ផែនដីទុកជាកម្មសិទ្ធិផ្ទាល់របស់ខ្លួន គឺយើងមានសិទ្ធិជិះជាន់ផែនដី និងប្រើប្រាស់បានតាមអំពើចិត្ត ចិត្តយើងរបួសដោយបាបហិង្សាដែលមានកប់ទុកក្នុងចិត្តមនុស្សយើង បណ្តាលឲ្យផែនដីមានជំងឺ ដូចយើងឃើញរោគសញ្ញាផ្សេងៗក្នុងដី ក្នុងទឹក ក្នុងខ្យល់ នៅក្នុងសត្វលោកទាំងឡាយ។ ហេតុនេះហើយ បានជាផែនដីយើងដែលមនុស្សជិះជាន់នោះ ស្ថិតនៅក្នុងចំណោមអ្នកក្រីក្រ ដែលមនុស្សលោកមិនអើពើខ្លាំងជាគេ។ ផែនដីដែលមនុស្សបំផ្លាញនោះ កំពុងតែស្រែកថ្ងូរ និងឈឺចុកចាប់ដូចជាស្ត្រីដែលហៀបនឹងសម្រាលកូន។ យើងបានភ្លេចថា យើងគ្រាន់តែជាធូលីដីតែប៉ុណ្ណោះ រូបកាយរបស់យើងក៏ផ្សំដោយធាតុផ្សេងៗនៃពិភពលោក គឺខ្យល់របស់ផែនដីផ្តល់ឲ្យយើងអាចដកដង្ហើមបាន ទឹកនៃផែនដីក៏ផ្តល់ជីវិតឲ្យយើង និងផ្តល់កម្លាំងឲ្យយើងដែរ**"។ ដើម្បីឲ្យយើងចាប់អារម្មណ៍អំពីតួនាទីរបស់យើងផ្ទាល់ ផែនដីរបស់យើងកំពុងស្រែកយំដូចស្ត្រីដែលកំពុងឆ្លងទន្លេ ណែនាំឲ្យយើងយល់ថាផែនដីរបស់យើងធ្វើឲ្យយើង

មានដង្ហើម ធ្វើឲ្យយើងមានជីវិត ធ្វើឲ្យយើងមានកម្លាំង ធ្វើឲ្យយើងមានវត្តមានសព្វថ្ងៃ។ ប្រសិនបើមនុស្ស ចេះតែបំផ្លាញផែនដីរបស់យើង បីដូចជាបំផ្លាញជីវិតរបស់ខ្លួនឯងផ្ទាល់ ជាពិសេសក្មេងៗជំនាន់ក្រោយទៀត។

ខ្ញុំសូមអរគុណដល់អនុប្រធានមន្ទីរ ដល់លោកសាស្ត្រាចារ្យដែលបានធ្វើបទបង្ហាញអំពីបរិស្ថាន អរគុណដល់គណកម្មការរៀបចំសិក្ខាសាលានេះ។ ថ្ងៃនេះយើងបានយល់ថា ផែនដីជាម្តាយរបស់យើង ជាបងស្រីរបស់យើង នឹងយើងត្រូវរួមគ្នាទទួលខុសត្រូវ។

**ទីមួយ** យើងយល់អំពីរួមគ្នាមានន័យយ៉ាងណា គឺមានន័យថាក្រុមគ្រួសារនីមួយៗ ភូមិរបស់យើង អាជ្ញាធររបស់យើង សាលានីមួយៗ វត្តអារាមនៅក្នុងទីតាំងដែលយើងរស់នៅ យើងត្រូវតែទទួលខុសត្រូវ។ ប៉ុន្តែ យើងមិនត្រូវគិតតែអំពីអាជ្ញាធរដីតែប៉ុណ្ណឹង យើងត្រូវការគិតដល់កម្រិតជាតិដែរ។ ដូច្នេះ នេះជារដ្ឋាភិបាលរបស់យើងដែលទទួលខុសត្រូវដែរ យើងមិនគិតតែប្រទេសកម្ពុជា ឲ្យយើងគិតអំពីពិភពលោក។ កាលពីខែធ្នូ ឆ្នាំ២០១៥ គ្រប់អ្នកដឹកនាំប្រទេសនៅក្នុងពិភពលោកទាំងមូល ប្រហែល១៦៥ប្រទេស បានជួបជុំគ្នានៅទីក្រុងប៉ារីសប្រទេសបារាំង ដើម្បីសម្រេចចិត្តរួមគ្នាសហការគ្នា ដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ ក្នុងនេះមាន ព្រះមហាក្សត្រ សីហមុនី ទ្រង់ចូលរួមជាតំណាងឲ្យប្រទេសកម្ពុជា នេះជារបៀបសហការរបស់ពិភពលោកទាំងមូល។ នៅខែមេសា ឆ្នាំ២០១៦ នៅញូយ៉កសហរដ្ឋអាមេរិក ប្រទេសទាំងអស់បានចុះហត្ថលេខារួចហើយ ឥលូវនេះតាមប្រទេសនីមួយៗ តាមរដ្ឋសភាត្រូវការបញ្ចេញច្បាប់មួយ ដើម្បីឲ្យយើងរួមគ្នាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

**ទីពីរ** យើងត្រូវយល់ថា នេះជាការទទួលខុសត្រូវរបស់យើងផ្ទាល់រៀងៗខ្លួន កុំឲ្យយើងទំ-លាក់លើរដ្ឋាភិបាល ទំលាក់លើសាលារៀន ទំលាក់លើអាជ្ញាធរដី តែនេះជាការទទួលខុសត្រូវរបស់យើងរៀងៗខ្លួន។

- យើងត្រូវការបង្កើតវប្បធម៌ថ្មី ជាវប្បធម៌ការពារថែរក្សាធម្មជាតិ ដោយសារយើងស្រឡាញ់ធម្មជាតិរបស់យើង។ យើងស្រឡាញ់ធម្មជាតិដូចម្តាយរបស់យើង ដោយសារបើឥតមានផែនដីចិញ្ចឹមយើង នោះយើងក៏ឥតមានជីវិតដែរ។ ពេលយើងគិតដូចនេះ ណែនាំឲ្យយើងបង្កើតទំនាក់ទំនងថ្មីជាមួយធម្មជាតិ។
- កុំឲ្យយើងភ្លេចអត្ថន័យរបស់បរិស្ថាន ទាំងបរិស្ថានធម្មជាតិ ទាំងបរិស្ថានសង្គមវប្បធម៌ និងបរិស្ថានមនុស្ស យើងទទួលបរិស្ថានទាំងអស់ ជាម្តាយរបស់យើង។
- យើងធ្វើដូចម្តេច ដើម្បីគោរព ស្រឡាញ់ ថែរក្សាបរិស្ថាន បីដូចជាយើងគោរព ស្រឡាញ់ ថែរក្សា ម្តាយរបស់យើងបង្កើតដែរ?

- ឲ្យយើងយកចិត្តទុកដាក់ជាមួយបរិស្ថានរបស់យើង ដោយការពារថែរក្សាដើមឈើ បើយើងកាប់ដើមឈើមួយដើម យើងត្រូវការដាំវិញពីរដើម។ មានប្រទេសខ្លះដូចជាសឹង្ហបូរី និងចិន នៅពេលគេសាងសង់អាគារមួយ គេត្រូវទុកកន្លែងមួយដើម្បីដាំដើមឈើ ប្រសិនបើឥត រដ្ឋាភិបាលមិនអនុញ្ញាតឲ្យសាងសង់ឡើយ។
- ថង់ប្លាស្ទិច ជាបញ្ហាមួយយ៉ាងធំដោយសារប្រទេសយើង ជាប្រទេសដែលចោលប្លាស្ទិចច្រើនជាងគេ។ សព្វថ្ងៃនៅអឺរ៉ុប ពេលគេទៅផ្សារអ្នកលក់លែងឲ្យប្លាស្ទិចអស់ហើយ ហេតុនេះហើយគេត្រូវការយកកាបូបធ្វើដោយក្រណាត់ពីផ្ទះមក។
- ម្យ៉ាងទៀត យើងគួរជំរុញបន្ថែម ធ្វើដូចម្ដេចដើម្បីឲ្យយើងមានបង្គន់អនាម័យនៅគ្រប់ទីកន្លែង? នៅតាមភូមិយើងដឹងថា សព្វថ្ងៃតាមផ្ទះនីមួយៗមិនទាន់មានបង្គន់អនាម័យគ្រប់គ្នានៅឡើយទេ។
- សម្រាប់បងប្អូនដែលចិញ្ចឹមជ្រូក មានអង្គការមួយបានជួយឧបត្ថមខ្លះ ដើម្បីសាងសង់បាយអូហ្គាស នេះមានប្រយោជសម្រាប់យើង ដោយសារយើងអាចមានភ្លើងប្រើប្រាស់បាន។
- ឲ្យយើងកែច្នៃសម្រាមរបស់យើង មួយចំនួននៃសម្រាមយើងអាចធ្វើជាជីកំប៉ុសធម្មជាតិ មួយចំនួនទៀតយើងអាចកែច្នៃបាន។ យើងត្រូវចោលសម្រាមឲ្យមានប្រភេទច្បាស់លាស់ សម្រាមដែកផ្សេង សម្រាមជ័រផ្សេង សម្រាមក្រដាស់ផ្សេង សម្រាមដែលអាចធ្វើជាកំប៉ុសផ្សេង សម្រាមដែលមានវិទ្យុសកម្មផ្សេង។
- ដូច្នេះអ្វីដែលសំខាន់បំផុតសម្រាប់យើងម្នាក់ ឲ្យចាប់ផ្ដើមមានពេលក្នុងដៃយើងមានសម្រាមមួយ យើងមិនបោះចោលតាមរបៀបមុនទេ គឺយើងបោះចោលនៅកន្លែងដែលច្បាស់លាស់ ឲ្យទៅជាវប្បធម៌មួយ។
- អំពីសម្រាមស្មោរសម្រាប់កូប៉ាយ ត្រូវការពេលវេលា១លានឆ្នាំទើបវារលាយ ដបទឹកសុទ្ធ១០០ឆ្នាំ ពេលយើងចោលនៅក្នុងដីវាមិនងាយរលួយទេ។ ដូច្នេះ យើងធ្វើដូចម្ដេចដើម្បីបង្កើតវប្បធម៌ថ្មីនេះ ឲ្យក្មេងៗយល់ថាពេលយើងបោះចោលសម្រាមខុសហើយ។
- ឲ្យក្មេករបស់យើងរៀន អំពីរបៀបដែលយើងត្រូវតែស្រឡាញ់ ស្រឡាញ់ធម្មជាតិ ស្រឡាញ់អនាម័យ។ បើកន្លែងយើងមានអនាម័យល្អ ពេលមានគេចូលមកធ្វើឲ្យគេមានភាពសុខដមរមនា។ ហេតុនេះហើយធ្វើដូចម្ដេច ដើម្បីឲ្យទៅជាធម្មជាតិរបស់យើងឲ្យក្មេករបស់យើងដឹងភ្លាមថា ពេលឥតមានអនាម័យឈឺចិត្តណាស់ ដូច្នេះ យើងធ្វើយ៉ាងណា ដើម្បីកែច្នៃឲ្យយើងមានអនាម័យយ៉ាងច្បាស់លាស់ នេះជា

របៀបដែលយើងម្នាក់ៗ អាចចូលរួមក្នុងការទទួលខុសត្រូវការពារបរិស្ថានធម្មជាតិ ការពារបរិស្ថានសង្គមវប្បធម៌ ការពារបរិស្ថានមនុស្ស ដោយសារយើងជាមនុស្សដែលរស់នៅក្នុងបរិស្ថាននេះ។

ខ្ញុំសង្ឃឹមថាសិក្ខាសាលានេះអាចជួយខ្លះៗ ដើម្បីឲ្យយើងភ្ញាក់ស្មារតី ឲ្យយើងចេះស្រឡាញ់បរិស្ថានរបស់យើងថែមទៀត បីដូចជាម្តាយបង្កើតរបស់យើង ដែលចិញ្ចឹមយើងពីមួយថ្ងៃទៅមួយថ្ងៃ។

ទីបី យើងត្រូវតែបន្ថែមការអប់រំ ការណែនាំ ដើម្បីឲ្យសិក្ខារបៀបនេះទៅផ្សព្វផ្សាយតាមភូមិនីមួយៗ។ ខ្ញុំចង់ឲ្យភូមិនីមួយៗអាចក្លាយជាភូមិបៃតង យើងអាចរៀបចំការប្រកួតមួយ ដើម្បីឲ្យភូមិនីមួយៗថែរក្សាបរិស្ថាន។ យើងរៀបចំគណកម្មការមួយ ដើម្បីតាមដានតាមភូមិនីមួយៗ ដើម្បីដឹងថាភូមិនីមួយៗ យកចិត្តទុកដាក់ការពារបរិស្ថានកម្រិតណា។ នេះអាជ្ញាធររៀបចំជាមួយប្រជាជនតាមផ្ទះនីមួយៗ គ្រួសារដែលបានដាំដើមឈើច្រើន គ្រួសារដែលបានការពារអនាម័យបរិស្ថាន ហើយមួយឆ្នាំម្តងយើងជូនរង្វាន់ភូមិណាដែលបានការពារបរិស្ថានលេខមួយ។ យើងមាន៣០ភូមិនៅក្នុងឃុំគុសយើង ឲ្យយើងរៀបចំការប្រកួតអនាម័យតាមភូមិ មួយឆ្នាំម្តងគណកម្មការចុះតាមភូមិដើម្បីវិនិច្ឆ័យ ដោយរៀបចំកម្រងសំនួរច្បាស់លាស់ អំពីអនាម័យតាមផ្ទះ អំពើដើមឈើ អំពីសោ-ភ័ណ្ឌភាព អំពីបង្គន់អនាម័យ ហើយដាក់ពិន្ទុ។ អ្នកដែលបានទទួលពិន្ទុច្រើនជាគេ បានទទួលរង្វាន់ដែលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញរៀបចំជាមួយឃុំ។

យើងចូលរួមដើម្បីបង្កើតភូមិបៃតង ដែលជាភូមិការពារថែរក្សាទាំងធម្មជាតិ ទាំងសង្គមវប្ប-ធម៌ ទាំងមនុស្ស ដើម្បីរួមគ្នាយើងដឹងថាយើងបានទទួលមរតកមួយយ៉ាងអស្ចារ្យ គឺផែនដី ដែលទ្រព្យសម្បត្តិនេះ យើងត្រូវការថែរក្សាទុកផ្ទេរដល់កូនចៅរបស់យើងជាបន្តបន្ទាប់។ សូមអរគុណ។

ភូមិចំការទៀង ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧

លោកអភិបាលអូលីវីយេ